# ជំងឺកញ្ជ្រឹល

## កញ្ជ្រឹលគឺជាជំងឺដ៏ធ្ងន់ធ្ងរមួយ



កញ្ជ្រឹល គឺជាជំងឺធ្ងន់ធ្ងរដែលបង្កឲ្យមានស្នាមកន្ទួលរមាស់ និងជំងឺគ្រុនក្តៅជំងឺកញ្ជ្រឹល គឺជាជំងឺឆ្លង។

វាឆ្លងរីករាលដាល នៅពេលដែលមនុស្សម្នាក់កើតជំងឺកញ្ជ្រឹលបញ្ចេញខ្យល់ដង្ហើម ក្អកឬកណ្តាស់។

អ្នកដែលមិនបានចាក់វ៉ាក់សាំងបង្ការ គឺអាចនឹងងាយឆ្លងជំងឺកញ្ជ្រឹលជាងមនុស្សធម្មតា។

ជំងឺកញ្ជ្រឹលអាចនឹងមានគ្រោះថ្នាក់ ជាពិសេសសម្រាប់ទារក និងកុមារតូចៗ។ ករណីខ្លះ ជំងឺនេះអាចនឹងបង្កគ្រោះថ្នាក់ដល់អាយុជីវិតបាន។

## ការពារគ្រួសារអ្នកពីជំងឺកញ្ជ្រឹល



វិធីដ៏ល្អបំផុតក្នុងការការពារគ្រួសារអ្នកពីជំងឺកញ្ជ្រឹល គឺត្រូវចាក់វ៉ាក់សាំងបង្ការ។ គ្រូពេទ្យណែនាំថា កុមារទាំងអស់ត្រូវទទួលថ្នាំវ៉ាក់សាំង MMR។

ការទទួលថ្នាំវ៉ាក់សាំង MMR គឺមានសុវត្ថិភាព និងមានប្រសិទ្ធិភាពក្នុងការបង្ការជំងឺកញ្ជ្រឹល។ វាក៏ជួយ ការពារប្រឆាំងទៅនឹងជំងឺសាទ្បាទែន និងជំងឺស្អូចបានផងដែរ។

ការទទួលថ្នាំវ៉ាក់សាំង MMR គឺមានសុវត្ថិភាពជាងការបណ្តោយខ្លួនឲ្យឆ្លងជំងឺកញ្ជ្រឹល។

កុមារភាគច្រើនមិនទទួលរងផលអវិជ្ជមានពីការចាក់ថ្នាំវ៉ាក់សាំងនេះឡើយ។ ផលអវិជ្ជមានរបស់ថ្នាំដែលកើតមាន ជាធម្មតាគឺមានតិចតួចបំផុត និងមិនមានរយៈពេលវែងនោះឡើយ ដូចជា៖ គ្រុនក្តៅ កន្ទួលរមាស់ និងការឈឺខ្លួនប្រាណ។

## ថ្នាំវ៉ាក់សាំង MMR មិនបណ្តាលឲ្យកើតមានជំងឺអូទីស៊ីមឡើយ

មិនមានការសិក្សាស្រាវជ្រាវណាមួយបង្ហាញអំពីទំនាក់ទំនាងរវាងជំងឺអូទីស៊ីម និងថ្នាំវ៉ាក់សាំង MMR នោះឡើយ។ បញ្ហានេះត្រូវបាន ក្រុមវេជ្ជបណ្ឌិត និងអ្នកវិទ្យាសាស្រ្តទូទាំងពិភពលោក បានធ្វើការសិក្សាស្រាវជ្រាវយ៉ាងប្រុងប្រយ័ត្នបំផុត។

អ្នកវិទ្យាសាស្រ្តនានាកំពុងសិក្សាស្រាវជ្រាវទៅលើបុព្វហេតុដែលអាចនឹងធ្វើឲ្យកុមារកើតមានជំងឺអូទីស៊ីម។អ្នកវិទ្យាសាស្រ្តភាគច្រើន យល់ស្របថា សែនតំណពូជរបស់គ្រួសារអាចជាបុព្វហេតុនាំឲ្យបុគ្គលម្នាក់អាចនឹងកើតមានជំងឺអូទីស៊ីម។ អ្នកវិទ្យាសាស្រ្តទាំងនោះក៏កំពុងសិក្សាផងដែរអំពីទំនាក់ទំនងរវាងជំងឺអូទីស៊ីម និងទីកន្លែងដែលមនុស្សរស់នៅ។

សូមសួរវេជ្ជបណ្ឌិតរបស់អ្នក ប្រសិនបើអ្នកមានសំណួរអំពីជំងឺកញ្ជ្រឹល ឬថ្នាំវ៉ាក់សាំង MMR។

**សម្រាប់ព័ត៌មានបន្ថែម៖**

www.doh.wa.gov/measles

http://kingcounty.gov/health/measles

Somali Health Board — Peace, Unity, Life, Health

Public Health Seattle & King County

Washington State Department of Health

# តើអ្នកត្រូវធ្វើដូចម្តេច ប្រសិនបើអ្នកគិតថាអ្នកមានជំងឺកញ្ជ្រឹល

## រោគសញ្ញានៃជំងឺកញ្ជ្រឹល និងលក្ខណៈនៃការឆ្លង

ជំងឺកញ្ជ្រឹលតែងចាប់ផ្តើមកើតមានតាមរយៈអាការគ្រុនក្តៅខ្លាំង ក្អក ហៀរសំបោរ ភ្នែកឡើងក្រហម និងហូរទឹកភ្នែក។ បន្ទាប់ពីរយៈពេល 3-4 ថ្ងៃក្រោយមក មានស្នាមរកន្ទួលរមាស់ចាប់ផ្តើមកើតមាននៅលើផ្ទៃមុខ និងរាលដាលទៅផ្នែកដទៃផ្សេងទៀតនៃរាងកាយ។

អ្នកអាចចម្លងជំងឺកញ្ជ្រឹលទៅមនុស្សផ្សេងទៀតបាននៅពេលអ្នកមានរោគសញ្ញាទាំងនេះ។ អ្នកនឹងចម្លងជំងឺនេះរហូតដល់ ស្នាមកន្ទួលរមាស់បាត់ទៅវិញ។

អ្នកអាចនឹងឆ្លងជំងឺកញ្ជ្រឹលបាន ដោយគ្រាន់តែស្ថិតនៅក្នុងបន្ទប់មួយដែលមានអ្នកជំងឺកញ្ជ្រឹលធ្លាប់ស្នាក់នៅ។

វីរុសកញ្ជ្រឹលស្ថិតនៅក្នុងខ្យល់រយៈពេលរហូតដល់ពីរម៉ោង បន្ទាប់ពីអ្នកជំងឺនោះចាកចេញពីបន្ទប់។

## សូមទូរសព្ទទៅកាន់វេជ្ជបណ្ឌិតរបស់អ្នកឬគ្លីនិកជាបន្ទាន់ ប្រសិនបើអ្នកពិនិត្យឃើញមានរោគសញ្ញាទាំងនេះ

វេជ្ជបណ្ឌិតរបស់អ្នកឬគ្លីនិក នឹងឲ្យអ្នកដឹងថា តើអ្នកចំបាច់ត្រូវចូលទៅកាន់គ្លីនិកដើម្បីធ្វើការពិនិត្យជំងឺដែរឬយ៉ាងណា។

ជំងឺកញ្ជ្រឹលគឺជាជំងឺងាយឆ្លង ហើយអ្នកអាចនឹងចម្លងជំងឺនេះទៅអ្នកដទៃទៀតនៅក្នុងបន្ទប់រង់ចាំ។ ចាំបាច់ត្រូវប្រាប់វេជ្ជបណ្ឌិតរបស់អ្នក ឬគ្លីនិកថា អ្នកមានរោគសញ្ញាជំងឺកញ្ជ្រឹល **មុនពេល**អ្នកទៅកាន់គ្លីនិក។ ពួកគេនឹងផ្តល់ការណែនាំដល់អ្នកអំពីអ្វីដែលអ្នកត្រូវធ្វើ ដើម្បីកុំឲ្យអ្នកចម្លងជំងឺកញ្ជ្រឹលនេះបាន។

## ត្រូវនៅផ្ទះ ប្រសិនបើអ្នកមានជំងឺកញ្ជ្រឹល

ចាំបាច់ មិនត្រូវចម្លងជំងឺកញ្ជ្រឹលទៅអ្នកដទៃឡើយ។

ត្រូវនៅផ្ទះ ប្រសិនបើអ្នកមានជំងឺកញ្ជ្រឹល។ មិនត្រូវទៅសាលារៀន កន្លែងធ្វើការ ទៅហាងលក់ទំនិញ ឬផ្ទះរបស់អ្នកដទៃផ្សេងទៀតឡើយ។

មិនត្រូវមានអ្នកមកសួរសុខទុក្ខនៅផ្ទះរបស់អ្នកឡើយ ប្រសិនបើអ្នក ឬកូនរបស់អ្នកមានអាការៈគ្រុនក្តៅ ឬស្នាមកន្ទួលរមាស់។

## សម្រាប់ព័ត៌មានបន្ថែម៖

www.doh.wa.gov/measles
http://kingcounty.gov/health/measles

DOH 348-651 , August 2017 Khmer

Public Health
Seattle & King County

Somali Health Board
Peace, Unity, Life, Health

Washington State Department of Health

ឯកសារនេះអាចស្វែងរកបានជាទម្រង់ផ្សេងទៀត សម្រាប់អ្នកដែលមានពិការភាព។
ដើម្បីដាក់ពាក្យស្នើសុំ សូមទូរសព្ទទៅលេខ 1-800-525-0127 (TTY/TDD 1-800-833-6388)។